**BMI0054**

# សម្ភាសជាមួយឈ្មោះ ឡែម សុខុម ភេទប្រុស អាយុ៨៩ឆ្នាំ

មុខងារខ្មែរក្រហមៈ ធ្វើនៅរោងចក្រដែកគោល

មុខងារបច្ចុប្បន្នៈ កសិករ

មានស្រុកកំណើតនៅៈ ភូមិក្អែងខ្វា ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិវាលហាតិ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០០:៤៣:៥១

១៩ទំព័រ

ដានី : ដំបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ អ៊ំឈ្មោះអីដែរ?

សុខុម : ឈ្មោះ ឡែម សុខុម ។

ដានី : សព្វថ្ងៃអ៊ំអាយុប៉ុន្មានហើយ?

សុខុម : អាយុ៨៩ឆ្នាំ ។

ដានី : ភូមិនេះភូមិអីគេ?

សុខុម : ភូមិវាលហាត ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ដានី : គ្រួសារអ៊ំឈ្មោះអីដែរ?

សុខុម : ឈ្មោះ វ៉ាំ គឹមស៊ី!

ដានី : គាត់អាយុប៉ុន្មានដែរ?

សុខុម : គាត់អាយុ៨៩!

ដានី : អាយុ៨៩ដូចពូដែរ?

សុខុម : បាទ!

ដានី : ពូមានកូនចៅប៉ុន្មាននាក់ហើយសព្វថ្ងៃ?

សុខុម : កូនចៅបីនាក់!

ដានី : ស្រីប៉ុន្មានប្រុសប៉ុន្មាន?

សុខុម : ស្រីពីរនាក់ ប្រុសមួយ!

ដានី : សព្វថ្ងៃពូប្រកបរបររកស៊ីអីដែរ?

សុខុម ៖ ខ្ញុំប្រកបរបរធ្វើស្រែចំការ!

ដានី ៖ ចុះស្រុកកំណើតពូនៅណា?

សុខុម ៖ ស្រុកកំណើតខ្ញុំនៅតាកែវ!

ដានី ៖ នៅភូមិឃុំអីដែរតាកែវហ្នឹង?

សុខុម ៖ នៅតាកែវនៅស្រុកបាទី ឃុំចំបក់!

ដានី ៖ ភូមិអីដែរ?

សុខុម ៖ ភូមិក្លែងខ្លា!

ដានី ៖ ចុះឪពុកពូគាត់ឈ្មោះអីដែរ?

សុខុម ៖ ឪពុកម្ដាយខ្ញុំគាត់ស្លាប់អស់ហើយ!

ដានី ៖ គាត់ស្លាប់នៅជំនាន់ណា?

សុខុម ៖ ស្លាប់នៅជំនាន់៧២នេះមួយ ហើយនៅជំនាន់យើងផ្ដាច់ខ្លួននេះមួយ! កាលហ្នឹងគាត់ជាប់គុកព្រៃសហើយគេយកទៅវិញដូចថាគាត់គ្រាំគ្រាគាត់ណាស់ ។

ដានី ៖ ចុះកាល៧២គាត់ស្លាប់ដោយសារមូលហេតុអី?

សុខុម ៖ ឪពុកខ្ញុំគាត់ស្លាប់ដោយសារពិស!

ដានី ៖ គាត់ឈ្មោះអីដែរ?

សុខុម ៖ ឈ្មោះ ណែន យឹន ។

ដានី ៖ កាលគាត់កើតពិសហ្នឹងកើតនៅឆ្នាំណា?

សុខុម ៖ កាលឆ្នាំ៧២ហ្នឹង!

ដានី ៖ ចុះម្ដាយ?

សុខុម ៖ ម្ដាយស្លាប់មុនយើងផ្ដាច់ខ្លួនមួយឆ្នាំ ។

ដានី ៖ គាត់ស្លាប់ដោយសារមូលហេតុអីដែរ?

សុខុម ៖ គាត់ឈឺដោយសារគាត់គ្រាំគ្រាគាត់ពេក កាលហ្នឹងគេធ្វើបាបគាត់ខ្លាំងណាស់! ជាប់ទាំងអត់តែខ្ញុំមួយទេ មែនទែនទៅជាប់គុកតែទាំងអស់ហ្នឹង ។

ដានី ៖ ម្ដាយឈ្មោះអី?

សុខុម ៖ ឈ្មោះឌុច យួន!

ដានី ៖ ចុះគាត់ជាប់គុកដោយសារអី?

សុខុម ៖ ខ្ញុំអត់ដឹងដែរ ព្រោះយើងម៉ោភ្នំពេញយើងកុមារគេឲ្យយើងម៉ោធ្វើកម្មករណ៍ ដូច្នេះគាត់នៅនោះនៅមន្ទីរដល់ពេលនេះគេចាប់ពីមន្ទីរទៅយកទៅដាក់គុកហ្នឹង! ដល់ឆ្នាំ៧៩ បានគាត់ចេញពីគុក ។

ដានី ៖ អញ្ចឹងកាលពីមុនគាត់នៅក្នុងមន្ទីរសិប្បកម្ម មន្ទីរហ្នឹងនៅណា?

សុខុម ៖ នៅសំពៅងយ៉ោង ។

ដានី ៖ នៅសំពៅងយ៉ោង?

សុខុម ៖ បាទ!

ដានី ៖ ដល់ពេលក្រោយម៉ោគេចាប់គាត់ដាក់គុកព្រៃស?

សុខុម ៖ បាទ!

ដានី ៖ ពីឆ្នាំណាដល់ឆ្នាំណា?

សុខុម ៖ អត់ដឹងខ្ញុំដាច់ខ្លួនហើយខ្ញុំសួរបានដឹង! ព្រោះកាលហ្នឹងមានបានទាក់ទងគ្នាអីដូចឥលូវ! យើងអាប្អូនបែកម៉ោនេះតែមួយទៅ អានោះក៏ទៅចុះទៅ អាបងក៏ទៅចេះទៅ វាបាត់គ្នាបែកខ្ចាត់ខ្ចាយអស់ហើយធ្វើម៉េច ។

ដានី ៖ ចុះកាលពីមុនពូចេញពីផ្ទះកាលហ្នឹងគ្រួសារពូធ្វើអីទៅ?

សុខុម ៖ ធ្វើស្រែ ស្រុកនោះអត់មានអីក្រៅពីចំការទេ ធ្វើស្រែសុទ្ធៗ បើនេះមានស្រែមាន ចំការ បើនោះមានតែស្រែទេ ស្រុកបាទីអ្នកណាក៏ស្គាល់ដែរមានតែស្រែទេ ភ្នំតាម៉ៅគេមិនឲ្យកាប់ព្រៃទេតាំងពីដើមម៉ោ ។

ដានី ៖ បងប្អូនប៉ុន្មាននាក់ដែរពូ?

សុខុម ៖ បងប្អូនខ្ញុំ៦នាក់ ។

ដានី ៖ កាលមុនចេញពីផ្ទះនៅជួបជុំគ្នាទេ?

សុខុម ៖ អត់ជួបជុំគ្នាទេនៅបែកគ្នារហូត កងចល័តគេយកទៅនេះមួយ យកទៅនោះមួយគេយកទៅប្រើយើងផ្តេសផ្តាស ដល់យើងបែកគ្នាគេយកយើងម៉ោនេះមួយតែឯងម៉ោគេយកទៅប្រើ មិនមែនយើងចង់ធ្វើខ្លួនយើងណា ។

ដានី ៖ កាលហ្នឹងពូមានបានរៀនសូត្រទេ?

សុខុម ៖ គ្មានបានរៀនសូត្រទេ អត់បានរៀនទេ! បានរៀនសាលាវត្តបានរៀនបានបន្តិចកាល ហ្នឹងដល់ក្រោយម៉ោឆ្នាំ៧៣ហ្នឹង B៥២ ដាក់ច្រើនពេកទៅក៏យើងអត់បានរៀន រត់បាក់បែកគ្នាអស់ទៅ គេយកទៅកងកុមារដោយកុមារ មនុស្សចាស់ដាក់តាមមនុស្ស

ចាស់ទៅ  យើងបែកម៉ែឪតាំងពីហ្នឹងម៉ោរហូតម៉ោ  ដល់ឆ្នាំ៧៥នេះគេយកម៉ោភ្នំពេញម៉ោឲ្យធ្វើកម្មករ  ដល់ឆ្នាំ៧៩នេះគេជម្លៀសម៉ោទៀតក៏យើងចេះតែម៉ោៗតាមគេម៉ោរហូតអញ្ចឹងម៉ោ ។

ដានី : ចុះអញ្ចឹងឆ្នាំ៧៣ហ្នឹងយើងបែកចេញពីផ្ទះហើយ?

សុខុម : បាទ!ខ្ញុំបែកចេញពីផ្ទះហើយ  អត់បាននៅជាមួយម៉ែឪទេ ។

ដានី : មូលហេតុអីបានគេបំបែកព្រោះទឹមឆ្នាំ៧៣ហ្នឹង?

សុខុម : មិនដឹងមូលហេតុអីខ្ញុំក៏មិនដឹងដែល  បើគេបំបែកយើងអញ្ចឹងម៉ង  គេឲ្យយើងទៅកន្លែងកងកុមារទៅ ។

ដានី : កាលហ្នឹងពូអាយុប៉ុន្មាន?

សុខុម : មិនដឹងអាយុប៉ុន្មានទេ  ដូចអាយុ១០ឆ្នាំជាងមិនដឹង  មិនធំប៉ុន្មានទេតូចដឹងស្រពិច  ស្រពិល ។

ដានី : កងចល័តនៅឆ្ងាយពីផ្ទះទេ?

សុខុម : វាមិនឆ្ងាយប៉ុន្មានទេ  តែគេមិនឲ្យយើងទៅ ។

ដានី : ចុះដល់ពេលឆ្នាំ៧៥នេះគេរើសយើងម៉ោភ្នំពេញវិញ?

សុខុម : បាទ!គេរើសមកភ្នំពេញវិញ ។

ដានី : អ្នកនៅកងចល័តទាំងអស់គេរើសម៉ោទាំងអស់?

សុខុម : អត់ទេគេរើសតាមបុគ្គលទេ  ដូចថាបុគ្គលណាដូចថាមានឆ្លាតប្រាជ្ញាខាងគ្រឿងចក្រខាងម៉ាស៊ីនអញ្ចឹងគេរើសយកម៉ោ  ដូចថាកុមារណាវាអត់ឆ្លាតគេអត់យកម៉ោទេ  ក្មេងណាដែលមានដុងគេយកម៉ោទៅ ។

ដានី : កាលហ្នឹងពូម៉ោនៅភ្នំពេញនៅកន្លែងណាទៅ?

សុខុម : នៅកន្លែងជិតចាក់អង្រែ  នៅជិតសាលាខេត្តតាខ្មៅហ្នឹង  នៅរោងចក្រដែកគោល ។

ដានី : ធ្វើអីទៅកាលហ្នឹង?

សុខុម : ធ្វើដែកគោល  រោងចក្រហ្នឹងវាមានធ្វើពីរធ្វើដែកគោលហ្នឹងផង  ធ្វើខ្សែលីងឡុងផង  គេចេះតែឲ្យយើងធ្វើទៅ  យើងចេះតែរៀនទៅ  មានកម្មករនៅចាស់ៗ១-២នៅ  ក្រោយម៉ោគេយកកម្មករចាស់ៗធំៗដូចខ្ញុំអីគេយកទៅអស់ទៅ  គេយកទៅរៀនសូត្រទៅហើយយើងគេបន្តអាតូចៗហ្នឹងឲ្យរៀនបន្តៗទៀតណាស់ ។

ដានី : ដំបូងគេឲ្យយើងរៀនសូត្រពីកម្មករចាស់ៗ?

សុខុម : ហ្នឹងហើយ គេមានកុមារ មានមនុស្សកំលោះ ដូច្នេះអាកំលោះហ្នឹងគេចេះខ្លះៗទៅ គេសុំកម្មករចាស់ហ្នឹងយកទៅ មិនដឹងគេយកទៅណាគេ គេថាយកទៅរៀនសូត្រមិនដឹងគេដែរ យើងក៏មិនហានសួរគេទេ ។

ដានី : ហើយចុះដល់ពេលអញ្ជឹងទៅ គេយកទៅអស់ទៅយើងនៅកម្មករក្មេងៗហ្នឹងយើងធ្វើខ្លួនឯងទៅ?

សុខុម : បាទ!គេយកទៅអស់ កម្មករដែលកំលោះៗ វាពេញកំលោះអាយុ២០-២១ហ្នឹងចេះ វាចាប់ផ្ដើមចេះហើយ ១ឆ្នាំក្រោយម៉ោវាចេះហើយចេះជួសជុលម៉ាស៊ីនវាខូចថាធ្វើអី វាខូចអី តែ១ឆ្នាំចេះហើយ ខ្លះអត់ទេដូចខ្ញុំអីតែ២-៣ខែចេះហើយ ។

ដានី : ធ្វើនៅក្នុងរោងចក្រហ្នឹង?

សុខុម : ហ្នឹងហើយធ្វើជុសជុលម៉ាស៊ីនដែលខូចអីកែអី ហើយខូចអាណាផ្លាស់អាណាវិញហ្នឹងណា៎ មានទៅធ្វើអី ។

ដានី : នៅកន្លែងតាខ្មៅហ្នឹង?

សុខុម : បាទ!នៅហ្នឹង នៅចាក់អង្រែហ្នឹងនៅជិតតាខ្មៅហ្នឹង ដីប្រហែលជា២០០ម៉ែត្រពីសាលាខេត្ត ។

ដានី : ចុះពេលហ្នឹងមានបានមកលេងផ្ទះទេ?

សុខុម : អត់បានទេ!គេមិនឲ្យយើងម៉ោទេ ។

ដានី : ចុះហូបចុកវិញយ៉ាងម៉េចដែរ?

សុខុម : ហូបចុក អ៊ូ!វេទនាណាស់ មុនដំបូងនោះហូបនំប៉័ងម៉ាពេលមិនដល់មួយកំណាត់ទេ គេយកម៉ោមុនដំបូង នំប៉័ងជាមួយសម្លយើងហ្នឹងហូបទៅ ។

ដានី : ហូបនំប៉័ងរហូតរាល់ថ្ងៃ?

សុខុម : ហូបនំប៉័ងបានមួយឆ្នាំមិនដឹងបានបាយជាមួយពោត ក្រោយម៉ោបានបាយលាយចេក ក្រោយមកទៀតលាយជាមួយចេក អស់ពីលាយជាមួយចេក លាយជាមួយគល់ចេកទៀត នៅភ្នំពេញហ្នឹងយ៉ាប់ដែរ ។

ដានី : ចុះម៉េចបានហូបនំប៉័ងព្រោះខ្មែរយើងទំលាប់ហូបបាយ?

សុខុម : វាអត់ដឹងដែរ គេថាអង្គការគេឲ្យធ្វើអញ្ចឹងមួយថ្ងៃមួយទេ ប៉ុន្តែមែនទែនយើងឃើញនំប៉័ងអត់ដល់មួយទេ ហើយហូបជាមួយសម្លយើងហ្នឹង ប្រវែងនេះទេ នំប៉័ងគេអាមួយ ១ពាន់ខ្មែរយើងហ្នឹង ប៉ុនអត់ដល់មួយកំណាត់ទេណា៎មួយពេល ។

ដានី ៖ ចុះស្អែតប្អូនអត់?

សុខុម ៖ មានអីទៅស្អែត តែបើយើងមិនស្អែតក៏យើងមិនហានថា ហានថាអីប្រើងតែធ្វើការទៅ ចុះបើយើងមិនស្អែតយើងទៅទាណាទៀត យើងមានម៉ែឪយើងឯណា យើងនៅជាមួយឲ្យគេធ្វើម៉េច បើគេកំណត់ជាទូទៅអញ្ចឹងយើងទៅហានទាធ្វើម៉េច មិនស្អែតគឺអត់ហើយ ដល់ម៉ោងទៅធ្វើការយើងធ្វើទៅ ។

ដានី ៖ យើងធ្វើការរហូតគេអត់មានឲ្យយើងរៀនអីទេ?

សុខុម ៖ រៀនៗខ្លះដែរ រៀនពេលយប់ខ្លះដែរមិនអត់ទេក្រោយម៉ោបានមួយឆ្នាំបានរៀនពេល យប់ពេលយប់គេឈប់ឲ្យកូនក្មេងធ្វើហើយ រៀនពីម៉ោង៨ដល់ម៉ោង៩អញ្ចឹងទៅ ដូចថាមានបងៗយុវជនចាស់ៗគាត់ចេះ គាត់បង្រៀននៅក្នុងរោងចក្រហ្នឹងតែម្ដងអត់ឲ្យមកចេញមកសាលាណាទេ កូនក្មេង៤-៥នាក់ហ្នឹងនៅរៀននៅហ្នឹង ។

ដានី ៖ យើងរៀនអក្សរឬរៀនពីបច្ចេកទេសធ្វើ?

សុខុម ៖ រៀនអក្សរក៏រៀន បើបច្ចេកទេសគេរៀនជាទូទៅ បើរៀនអក្សរយើងរៀនជាទូទៅ បើរៀនបច្ចេកទេសវាមានថ្ងៃវា ដូចថ្ងៃ ១០-២០អញ្ចឹងគេត្រូវរៀនបច្ចេកទេសគេមកទាំងអស់គ្នាទៅគឺគេសម្រាក១ថ្ងៃហ្នឹងដើម្បីរៀនបច្ចេកទេស តែបើក្រុមបច្ចេក ទេសមានបច្ចេកទេសគេផ្សេង បើបច្ចេកទេសរោងចក្រហ្នឹងរៀនទាំងអស់គ្នាអាហ្នឹងវា អញ្ចឹង ។

ដានី ៖ បាទ!ចុះអ៊ំៗអីមានដែលមកសួរសុខទុក្ខអីទេ?

សុខុម ៖ មិនមានទេ!ម្ដាយខ្ញុំអត់មានដែលជួបមុខទេ ទៅហ្នឹងស្លាប់បណ្ដោយទៅផ្ដាច់ហើយខ្លួន ស្លាប់អត់ដែលបានជួបមុខទេ តាំងពីបែកម៉ោអត់ជួបមុខរហូត បានជួបតែបងៗ ខ្ញុំទេ ។

ដានី ៖ កាលពីសម័យ៣ឆ្នាំដូចថា ពូមានដែលជួបពួកគាត់ ពួកមេដឹកនាំទេ?

សុខុម ៖ ហ៊ឺ!ធ្វើម៉េចបានជួបលោកហើយ អត់ដែលជួបមុខគេរបៀបម៉េចទេ ។

ដានី ៖ អត់ដែលទៅសួរសុខទុកនៅក្នុងរោងចក្រអីទេ?

សុខុម ៖ ទោះគេទៅសួរក៏គេមិនប្រាប់យើងដែរ ពេលហ្នឹងគេហៅយើងទៅធ្វើការបាត់ គេនៅតែគ្នាគេទៅ យើងក៏មិនដឹង មិនដឹងអ្នកមួយធំឬតូចបើយើងមិនដឹង យើងមិនដឹងរឿងព្រោះខ្ញុំនៅតូចដែលសម័យនោះ ។

ដានី ៖ បាទ!អញ្ចឹងពូធ្វើនៅហ្នឹងរហូតដល់បែក៧៩ យួនចូល?

សុខុម ៖ ហ្នឹងហើយ!

ដានី ៖ មានការផ្លាស់ប្ដូរដែរ?

សុខុម : បែក៧៩ យួនចូលគេជម្លៀសទៅ គេថាអើយ!កុមារៗគេងសិនទៅ យើងគេងតែ១ ថ្ងៃទេ ទំរាំគេរំដោះបានវិញយើងចូលម៉ោវិញហើយ ម៉ោអី ម៉ោខោម៉ាំចំកេះអាវម៉ាំ ចំកេះហ្នឹងអត់មានអីទេ ម៉ោចេញម៉ោៗទទេម៉ោចេះតែម៉ោៗរហូតម៉ោ ភ្នំបាសិតភ្នំអី ហ្នឹងចេះតែដើរម៉ោរហូតហ្នឹង ដើរដ៏ឆ្ងាយបរិល ។

ដានី : កាលហឹងមានក្មេងៗម៉ោពីស្រុកភូមិជាមួយពូដែរឬអត់?

សុខុម : មាន២-៣នាក់ កាលហ្នឹងគេម៉ោពីខេត្តផ្សេងៗចំរុះគ្នា ។

ដានី : ម៉ោធ្វើការនៅក្នុងរោងចក្រជាមួយគ្នាហ្នឹង?

សុខុម : បាទ!ម៉ោធ្វើការនៅក្នុងរោងចក្រជាមួយគ្នាហ្នឹង តែអ្នកខ្លះទៅខាងឯកទេសផ្សេងៗគ្នា ទៅ ។

ដានី : ចុះពេលដែលរត់ឆ្នាំ៧៩ហ្នឹងរត់មកជាមួយគ្នាដែរ?

សុខុម : រត់បែកគ្នាទៀត អត់បានជុំគ្នាទេ អាមួយទៅចេះអាមួយទៅចុះគេរើស ចូលមកដល់គេចាត់តាំងជាក្រុម ១០នាក់ទៅក្រុមនេះ ១០នាក់ទៅក្រុមនោះហើយអត់បាននៅក្រុមជាមួយគ្នាទេ បើយើងបានឈរជិតគ្នាគេហៅយើងឲ្យទៅទៀត សម័យនោះមានដូចសម័យនេះឯណា មិនចេះតែនៅក្រុមណាៗចេះតែបានណ៎អត់ទេ តែគេរាប់ហើយទៅ

ដានី : អញ្ចឹងកាលហ្នឹងដើររហូតតាំងពីភ្នំតាផ្តេមកដល់បវេលអី?

សុខុម : ដើររហូតមកដល់បវេល ។

ដានី : រយៈពេលប៉ុន្មានទៅមកដល់បវេល?

សុខុម : ហ៊ុ!យូរដែលហ្នឹង នៅប្រហែលជាកន្លះខែដែរ បានមកដល់បរិល

ដានី : អញ្ចឹងដូចថាហូបចុកអីយ៉ាងម៉េចដែរពេលរត់អញ្ចឹង?

សុខុម : យ៉ាប់ណាស់ពេលរត់ ដូចគ្នាម៉ោជាមួយបងអញ្ចឹង គ្នា៥០-៦០នៅក្នុងរោងចក្រម៉ោទាំងអស់គ្នា ជូនអីអង្ករ៤-៥កំប៉ុងបបរហូបទៅ ជូនអីក៏អត់ទៅ ម៉ោតាមផ្លូវមានតាឡូងក៏ដកតាឡូងដុតទៅចេះតែហូបឲ្យរស់ៗទៅ គេចេះតែខ្ញាំងមកដល់ហើយ យើងចេះតែរត់ៗទៅ ។

ដានី : ចុះពេលដែលយើងរត់ម៉ោអញ្ចឹងមានជួបប្រជាជនអីរត់ម៉ោជាមួយដែរឬអត់?

សុខុម : ប្រជាជនអត់មានទេ ស្ងាត់ឈឹងអស់រលីងម៉ងតាមភូមិអត់មានទេអត់មានប្រជាជនអី១ ទេ មិនដឹងទៅណាទេ ឃើញតែអ្នករត់ម៉ោ ហ្នឹងហើយឃើញតែកម្មកររត់ម៉ោ ។

ដានី : អត់មានឃើញប្រជាជនអី?

សុខុម ៖ អត់ៗមានឃើញទេ! វាឃើញដែរតែយើងដើរ៣-៤ភូមិឃើញមានប្រជាជន២-៣នាក់អញ្ចឹងទៅ ដល់មកដល់បវិលបានឃើញប្រជាជនលើកប្រឡាយលើកអី ។

ដានី ៖ ចុះកាលជំនាន់៣ឆ្នាំឬក៏ពេលរត់ហ្នឹង ពូមានដែលធ្លាប់ជួយអ្នកណាដូចជា គាត់អត់បាយអត់ទឹក គាត់ឈឺតាមផ្លូវអី យើងជួយឲ្យបាយឲ្យអង្ករឬក៏ឲ្យថ្នាំអី មានដែលបានជួយគេទេនៅពេលរត់?

សុខុម ៖ ខ្ញុំវាមិនបានជួយគេទេកាលខ្ញុំរត់ម៉ោហ្នឹង ពេលខ្ញុំរត់ម៉ោបាយខ្ញុំហូបសល់ ពេលខ្ញុំហូប សល់ប្រជាជនគាត់លើកព្រែកលើកប្រឡាយ ដល់ខ្ញុំអាបាយហ្នឹងវាធំពេកយកអត់រួចដល់ហើយមានតានោះគាត់ថាអាអូនណា៎ឲ្យបាយអ៊ំហូបផងកូនអ៊ំអត់បាយ២-៣ថ្ងៃ ហើយអ៊ំយកអានេះទៅខ្ញុំស្ពាយអត់រួចទេហើយគាត់យកហូបទៅ មានជួយអីគេអត់ទេមានតែគេជួយខ្ញុំមានតែខ្ញុំដើរអត់រួចគេលីខ្ញុំ ។

ដានី ៖ អ្ហូ!

សុខុម ៖ ហ្នឹងហើយព្រោះខ្ញុំនៅតូចដែរ បងៗហ្នឹងធំៗហ្នឹងគាត់ចេះតែអាវខ្ញុំទៅហើយ ហើយខ្ញុំថាខ្ញុំទៅមិនរួចទេ ខ្ញុំនៅនេះហើយ ហើយគាត់ថាតាឯងមិនទៅងាប់ គាត់ចេះស្រឡាញ់ ខ្ញុំឃើញក្មេងវាមានសុជីវធម៌គេចេះតែស្រឡាញ់ទៅ គេរវល់អាវ ហើយខ្ញុំដើរចេះតែដើរទៅ ដើរមិនរួចក៏អាវទៅ អញ្ចឹងទេ ។

ដានី ៖ កាលនោះអាយុប៉ុន្មានហើយពេលរត់?

សុខុម ៖ ១៦-១៧ហ្នឹងឯង ប៉ុនវាមានកម្លាំងឯណាបើវាអត់មានអីស៊ីនោះ វាគ្មានសាច់ដូចឥឡូវនេះណា៎ មនុស្សដើរតេវៗវីតៗហ្នឹង ។

ដានី ៖ កាលនៅកមករហ្នឹងអត់មានអីហូបចុកគ្រប់គ្រាន់ទេ?

សុខុម ៖ គ្មានអីហូបចុកគ្រាប់គ្រាន ទ៎

ដានី ៖ ចុះកាលជំនាន់៣ឆ្នាំហ្នឹង ពូមានដឹងថាមានការសម្លាប់មនុស្សដែរឬអត់?

សុខុម ៖ ទេ!ដូចខ្ញុំអត់ដឹង ដឹងដែរធ្លាប់ឮបងវ៉ាន់គាត់ថាគេយកទៅរៀនសូត្រដឹងតែអត់យកមកវិញទេ ហែងប្រយ័ត្នគេយកទៅរៀនសូត្រ ហែងតូចៗខ្ញុំថាគ្មានអ្នកណាគេយកទៅធ្វើអីទេខ្ញុំគ្មានចេះអីមួយអង្គុជង ប៉ុនឃើញហៅទៅរៀនឃើញបាត់ បាត់ហ្នឹងមិនដឹងគេយករៀនឯណា សួរបងៗទៅគាត់ថាគេផ្លាស់កន្លែងអង្គការគេយកទៅនោះ ភាគច្រើនខ្ញុំមិនសូវដឹងរឿងគេដែរ គេទៅណាក៏ទៅខ្ញុំអត់សូវដឹងរឿងគេទេ ដឹងតែគេឲ្យធ្វើការ ងារធ្វើ

គេឲ្យធ្វើអីដឹងតែធ្វើឲ្យគេទៅ បើខ្ញុំដឹងរឿងគេច្រើនដឹងតែខ្ញុំងាប់ ប៉ុនខ្ញុំអត់ដឹង ដឹងតែព្រឹកឡើងធ្វើការងារខ្ញុំទៅ ម៉ាស៊ីនណាខូចដឹងតែជុសជុលទៅ ។

ដានី : ចុះកាលហ្នឹងដូចថាយើងនៅក្មេងយើងបែកពីផ្ទះយើងនឹកផ្ទះយើងអត់មានសុំគេទៅលេងផ្ទះអីទេ?

សុខុម : វានឹងដែរ តែសុំគេ គេមិនឲ្យទៅ គេថាមានគ្នាគេរាប់ពាន់នាក់គេមិនឲ្យទៅផង ទៅបានតែឯងម្នាក់ម៉េច គេមិនឲ្យទៅៗទេ បើមិត្តឯងទៅមួយ ទាល់តែទៅទាំងអស់គ្នា ។

ដានី : ធ្លាប់សុំគេដែរ?

សុខុម : ខ្ញុំអត់ធ្លាប់សុំទេ បងសុំដល់ហើយអញ្ចឹងទៅ យើងម៉េចហានសុំគេទេ បងៗសុំទៅលេងផ្ទះអត់បានទៅផងពួកនៅព្រៃវែង នៅក្រចេះអីគេសុំទៅលេងផ្ទះនឹកផ្ទះដែរហ្នឹង គេមិនឲ្យទៅ បើឲ្យមិត្តឯងមួយគេមិនឲ្យទៅ ដល់ឲ្យទៅទាំងអស់គ្នាដល់អញ្ចឹងទៅ អាហ្នឹងយើងធ្វើម៉េច គេថាធ្វើម៉េចកុំឲ្យគេយកទៅរៀនសូត្រ ព្រោះអរៀនសូត្រមិនដែលឃើញម៉ោផង ។

ដានី : ដល់អញ្ចឹងពូរត់មកដល់បវិលហើយយ៉ាងម៉េចទៀតទៅ ដំណើរម៉េចទៀតទៅ?

សុខុម : គេ ពួកកងទ័ពគេយកឡានមកដឹកនៅប៉ៃលិននោះ គេយកពួកខ្ញុំទៅបំពាក់អាវុធនៅហ្នឹងឯង ។

ដានី : ពាក់អាវុធនៅណា?

សុខុម : នៅកោះឡាវក្រាវ ប៉ៃលិន ។

ដានី : កាលហ្នឹងចាប់ផ្ដើមចូលកងទ័ពហើយ?

សុខុម : ហ្នឹងហើយ ។

ដានី : កាលហ្នឹងទៅកងទ័ពខាងណា ខាងជម្រៀលប៉ៃលិនវិញ?

សុខុម : ហ្នឹងហើយ នៅជាមួយអ៊ីឈានកាលហ្នឹង ។

ដានី : យ៉ាងម៉េចទៅ នៅពេលដែលយើងចូលកងទ័ពដូចថាពេលកងទ័ពគេបំពាក់អាវុធហ្នឹង គេមុខព្រួញទៅខាងណា មុខព្រួញនៅម៉ាឡៃហ្នឹងឬមុខព្រួញ?

សុខុម : អត់ទេ! ត្រឹមតែខ្មែនទេ ត្រឹមខ្មែនទៅប៉ៃលិនទេ ។

ដានី : កាលហ្នឹងយើងវ៉ៃគេឬក៏យ៉ាងម៉េច?

សុខុម : ដល់ឯមនទែនទៅ មានកម្លាំងឯណាវ៉ៃគេ គ្រាន់តែគេដេញហ្នឹង ដេញចុះដេញឡើង បំពាក់អាវុធហើយ ទៅវ៉ៃការពាររថក្រោះដេញចង់ងាប់ចង់រស់ ម៉ោភ្នំកុយងាប់អស់

ប៉ុន្មានរយនាក់២-៣រយនាក់ បានតែទប់ទល់មានទៅគេអីឈ្នះ ក្រោយម៉ោក៏ធ្លាក់ទៅដីថៃទៅ ។

ដានី ៖ យើងអត់មានអាវុធគ្រប់គ្រាន់ អត់មានកម្លាំងឬក៏យ៉ាងម៉េច?

សុខុម ៖ អាវុធគ្រប់គ្រាន់ហើយ ប៉ុន្តែថាវាស្មារតីអត់មាន ។

ដានី ៖ ច្រើនទេកងទ័ពកាលហ្នឹង?

សុខុម ៖ ច្រើនដែរហ្នឹង កាលហ្នឹងអត់ទាន់មានប្រពន្ធទេ សុទ្ធតែនៅកំលោះទាំងអស់ ។

ដានី ៖ ចុះនៅទ័ពហ្នឹងរយៈពេលប៉ុន្មាន ហើយមានការផ្លាស់ប្ដូរដែរឬអត់?

សុខុម ៖ យូរដែរខ្ញុំត្រូវរបួសនៅខ្សែមហ្នឹង ត្រូវរបួសជើងអត់រួចទៅនៅដេកនៅខ្សែមហ្នឹង ក៏គេយកទៅជំរុំទៅ យកទៅជំរុំនៅឆ្នាំ៨២ក៏ខ្ញុំចេញទៅវិញទៅខ្មែរក្រហម ចេញពីខ្សែនមកនៅម៉ាឡៃវិញ ។

ដានី ៖ បាទ!កាលហ្នឹងត្រូវរបួសកន្លែងណា?

សុខុម ៖ ត្រូវរបួសនៅជើងដើរអត់រួចផង ដាច់សរសៃកែងមួយចំហៀង ដើរអត់រួចទេ ទៅដេកពេទ្យនៅព្រំដែន ជាហើយបានម៉ោវិញ ម៉ោវិញម៉ោនៅម៉ាឡៃ ។

ដានី ៖ យូរដែរព្យាបាលហ្នឹង?

សុខុម ៖ ដូចមិនយូរប៉ុន្មានទេ ដូចជា១ឆ្នាំដែរ ព្រោះសរសៃកែងហ្នឹងវាដាច់ម៉ាចំហៀងហើយដើរគ្មានរួចណា គេបង្រៀនយើងដើរតិចៗទៅ ។

ដានី ៖ ពេទ្យបារាំងអ្នកព្យាបាល?

សុខុម ៖ បារាំង ។

ដានី ៖ ដល់ពេលយើងជាទៅកងទ័ពខ្មែរក្រហមគេទោយកម៉ោ?

សុខុម ៖ ហ្នឹងហើយ គេៗមិនឲ្យម៉ោទេ តែខាងនេះគេយកទៅ ។

ដានី ៖ ចុះម៉េចបានយើងមិនទៅអន្តភាពចាស់វិញ ម៉ោខាងម៉ាឡៃវិញ?

សុខុម ៖ វាខាងនោះគេអត់ទោយក ។

ដានី ៖ អញ្ចឹងពេលរបួសជាម៉ោវិញម៉ោនៅណាដែរ?

សុខុម ៖ ម៉ោនៅហ្នឹងដដែល ។

ដានី ៖ កាលហ្នឹងគេហៅអីគេ កាលដែលម៉ោដំបូងដូចថាពេលដែលជាម៉ោហ្នឹងដំបូងគេហៅតំបន់អីទេ?

សុខុម ៖ អាហ្នឹងតំបន់ម៉ាឡៃហ្នឹង ។

ដានី ៖ ពីឆ្នាំប៉ុន្មានហ្នឹង?

សុខុម ៖ បើមិន៨១-៨២ហ្នឹងឯង ។

ដានី ៖ ចុះតំបន់ម៉ាឡៃហ្នឹងគេហៅតាំងពីអន្លង់វែងដែរ?

សុខុម ៖ អត់ដឹងដែរ ម៉ោដល់ឃើញតែគេហៅអញ្ចឹងម៉ង មិនដឹងរឿងដែរ ប៉ុនតាមដែលខ្ញុំដឹង ម៉ោឮតែគេអញ្ចឹង ឡែនៗ ប៉ៃលិនៗ ត្រាងៗ ដល់ម៉ោដល់ម៉ាឡៃៗឮតែគេថាទេ ។

ដានី ៖ អូ!ម៉ាឡៃពីមុនកងពលលេខប៉ុន្មានទៅ?

សុខុម ៖ មិនដឹងកងពលលេខប៉ុន្មានទេ ម៉ាឡៃមានតែ ៤៥០ហ្នឹងឯង ។

ដានី ៖ ម៉ាឡៃ៤៥០ ចុះខាងឡែនខាងអីកងពលលេខប៉ុន្មានទៅ?

សុខុម ៖ ដូចជា ៤៤០ឬ៤៣០ទេមិនដឹង ភ្លេចអស់ហើយយូរហើយ បើនេះ៤៥០ ។

ដានី ៖ ចុះកាលហ្នឹងយ៉ាងម៉េចទៅ ដូចថាម៉ោនៅម៉ាឡៃដំបូងយ៉ាងម៉េចទៅ ដូចថាមានធ្វើផ្ទះធ្វើសម្បែងដែរឬក៏អត់ទេ?

សុខុម ៖ ធ្វើតែគ្រាន់តែធ្វើតូចៗ សុទ្ធតែព្រៃទាំងអស់ហ្នឹង ។

ដានី ៖ អញ្ចឹងផ្ទះធ្វើនៅម៉ាម្ដុំណាទៅ?

សុខុម ៖ ធ្វើមានបាននៅជុំគ្នាណា ធ្វើម៉ាដុំៗតិចៗហ្នឹងនៅតែប្រពន្ធទាហានតិចៗហ្នឹង អាលោះៗមានបានទៅផ្ទះឯណា ចងតែអង្រឹងកៅស៊ូមួយទេ មានតែប្រពន្ធហើយនឹងពួកដឹកជញ្ជូនស្រីៗធ្វើផ្ទះនៅ ហើយនឹងពួកមន្ទីរនឹងគេនៅ បើចំពោះទាហានចំតួម៉ងអត់មានធ្វើផ្ទះទេ មានតែក្រណាត់កៅស៊ូមួយ ហើយអង្រឹងមួយទេ ។

ដានី ៖ ហើយចុះកាលហ្នឹងស្បៀងអាហារ ម្ហូប អង្ករអីបានពីណា?

សុខុម ៖ គេអ្នកផ្ដល់ឲ្យ មិនដឹងគេបានពីណាអត់ដឹងរឿងដែរ ។

ដានី ៖ ខាងដឹកជញ្ជូនគេយកមកឲ្យ?

សុខុម ៖ មិនដឹងខាងណាខាងណីទេយើងមិនដឹងទេ ខ្ញុំមិនសួរដឹងរឿងគេទេ គេយកមកឲ្យស៊ីៗទៅ គេមិនយកម៉ោអត់ទៅ មនុស្សខ្ញុំតាំងពីដើមអត់សួរចេះដឹងរឿងគេ ហែងធ្វើម៉េចៗទៅ ឲ្យតែបានឲ្យខ្ញុំស៊ី ។

ដានី ៖ នៅនោះដូចជាម្ហូបអីមានអីខ្វះទៅ?

សុខុម ៖ មានអីមានតែត្រីកាម៉ុងហ្នឹងឯង ប្រហុក ត្រីខ ។

ដានី ៖ អញ្ចឹងអង្ករអីគ្រប់គ្រាន់ទេ?

សុខុម ៖ អង្ករអីក្រោយម៉ោគ្រប់គ្រាន់ទេ តាំងពីខ្ញុំម៉ោនៅនេះម៉ោអត់អីទេ គ្រប់គ្រាន់ទេ ។

ដានី ៖ ចុះពូរៀបការនៅឆ្នាំណាទៅ?

សុខុម ៖ រៀបការឆ្នាំ៨៦ ។

ដានី ៖ រៀបការនៅណាកាលហ្នឹង?

សុខុម ៖ នៅដីថៃកាលហ្នឹង កាលហ្នឹងយើងជម្លៀសទៅថៃ ព្រោះវៀតណាមបាក់ទៅ ទៅនៅហ្នឹងហើយ ។

ដានី ៖ អូ៎!ខាងកងទ័ពខាងរដ្ឋកម្ពុជា ខាងវៀតណាមបានចូលមកដល់ហ្នឹងដែរ?

សុខុម ៖ ចូលមកដល់ហ្នឹង ហើយដេញពួកខ្មែរក្រហមទៅនោះ ហើយពួកក្រហមដេញ មកវិញដេញគ្នាទៅវិញទៅម៉ោ មុនដំបូងនៅហ្នឹង នៅហ្នឹងហើយរត់ទៅនោះ រត់ទៅនៅដីគេហើយម៉ោនេះវិញ ។

ដានី ៖ យូរដែរឬអត់ទៅនៅដីគេ?

សុខុម ៖ ៣-៤ឆ្នាំ ។

ដានី ៖ អញ្ចឹងយូរដែល ពួកខាងយួនគេមកនៅនេះយូរដែល?

សុខុម ៖ យូរហ្នឹងលែងបានទៅហើយ ទៅបានយូរៗមួយដង ស៊ីក្តាម ស៊ីខ្យង ។

ដានី ៖ អញ្ចឹងយើងទៅនៅដីថៃ កងទ័ពនៅតែចូលម៉ោអញ្ចឹង?

សុខុម ៖ ម៉ោៗនៅក្នុងហ្នឹងឯង គេមិនឲ្យម៉ោទេទាហាននោះ ម៉ោតែប្រពន្ធៗទេនៅកន្លែងជំរុំ ។

ដានី ៖ កាលហ្នឹងយ៉ាងម៉េចដែរការរៀបការ យើងឃើញគ្នាស្រឡាញ់គ្នារៀបការឬយ៉ាង ម៉េច?

សុខុម ៖ អត់ទេយើងស្រឡាញ់គ្នាធម្មតាគ្មានអ្នកណាបង្ខំយើងទេ យើងចូលសួរគេធម្មតា រៀបការដូចយើងធម្មតាអញ្ចឹង គ្រាន់តែវាគ្មានអីដូចឥឡូវ យើងមិនមានអីសំបូរបែបយើង ក្រយើងស្ថិតនៅក្នុងសង្រ្គាម មិនមែនដូចសម័យនោះឃើញគេចាប់យកៗគ្នានៅ ភ្នំពេញនៅមុខសាលាខេត្តនោះទេ អាហ្នឹងខ្ញុំឃើញមែន ឡានទៅដឹកៗមិនដឹងអ្នកណាប្តីអ្នកណាប្រពន្ធទេ ពួកអ្នកកាត់ដេហ្នឹង ។

ដានី ៖ ទៅដល់ចាប់គូរយកម៉ង?

សុខុម ៖ បាទ!នៅអន្លុយតុនឹង ខ្ញុំទៅដល់ឃើញ ខ្ញុំទៅធ្វើតភ្លើងនៅហ្នឹងគេដាច់ភ្លើង ទៅដល់ឃើញគេអន្លុយតុជាជួរៗហៅឈ្មោះឡើងអន្លុយលើតុៗ អើមិនបាច់ទេ ខ្លះមិនស្រឡាញ់គ្នាផងយកគ្នាធ្វើម៉េចទេ ខ្លះអត់ដែលស្គាល់គ្នាផង ។

ដានី ៖ ប្រពន្ធពូស្គាល់គ្នាពីមុនម៉ោ?

ប្រពន្ធ ៖ ចាំ!ស្គាល់គ្នា ។

សុខុម ៖ បាទ! ស្គាល់គ្នាយូរហើយ ។

ដានី ៖ គាត់នៅខាងជីកដញ្ជូន?

សុខុម ៖ នៅខាងសិល្បៈ ។

ដានី ៖ អញ្ចឹងបានស្គាល់គ្នា ទាក់ទងគ្នាយូរហើយបានរៀបការ?

សុខុម ៖ បាទ! យូរហើយ ។

ដានី ៖ ហើយការដូចយើងការធម្មតាមានម្ហូបមានអី?

សុខុម ៖ បាទ! ធម្មតាហ្នឹងហើយ ការធម្មតាយើងមានធនធានប៉ុន្មានយើងធ្វើប៉ុណ្ណឹង មុននឹងការយើងមិនចេះតែការណាយើងសុំគេសិន សុំមេបញ្ជាការគេជាមុនសិន ។

ដានី ៖ មេបញ្ជាការណាទៅ?

សុខុម ៖ បងអធិការហ្នឹង ហើយសុខ ភាពហ្នឹង សុំសុខ ភាពទៅ ។

ដានី ៖ សុខ ភាព គាត់ប្រធានកងពល?

សុខុម ៖ បាទ!

ដានី ៖ ចុះអធិការ?

សុខុម ៖ អធិការនោះគាត់ធ្វើប៉ូលីសតាំងពីដើមម៉ោ កាលនៅខ្មែរក្រហមក៏គាត់ធ្វើ ប៉ូលីសដែរ ។

ដានី ៖ កាលនោះមានប៉ូលីសដែរ?

សុខុម ៖ មានប៉ូលីស ។

ដានី ៖ ប៉ូលីសយ៉ាងម៉េចកាលជំនាន់នោះ?

សុខុម ៖ ប៉ូលីសដូចតែប៉ូលីសយើងឥឡូវហ្នឹងអញ្ចឹង ប៉ុនវាស្លៀកពាក់អាវអត់ដូចគ្នា ហើយវាមានផ្លាកដៃសំគាល់ថាប៉ូលីសអញ្ចឹងទៅ ។

ដានី ៖ ប៉ូលីសហ្នឹងយើងការពារ?

សុខុម ៖ ការពារខាងក្រោយ ។

ដានី ៖ ពី៨៩យើងម៉ោពីដីថៃយើងចូលមកវិញកាលហ្នឹងយ៉ាងម៉េចដែរ ដូចថាពេលដែលកងទ័ពយួនហើយនឹងរដ្ឋកម្ពុជាគេដកចេញវិញ កាលហ្នឹងយើងចូលម៉ោវិញ ឃើញស្ថានភាពនៅម៉ាឡៃហ្នឹងយ៉ាងម៉េចដែរ?

សុខុម ៖ ដូចមិនអីទេ វាលទទេសុទ្ធតែដីមីន យើងរាវមីនចេញធ្វើខ្ទមនៅទៅ ។

ដានី ៖ កាលហ្នឹងវាលទេ អត់មានព្រៃទេ?

សុខុម ៖ មានព្រៃដែរ តែយើងរាវទៅ កាប់ឈើកាប់អីធ្វើផ្ទះឲ្យប្រពន្ធយើងនៅទៅ ។

ដានី ៖ បាទ!ភាវមីនភាវអីខ្លួនឯង?

សុខុម ៖ បាទ!ភាវមីនដោយខ្លួនឯង ។

ដានី ៖ មីនច្រើនទេកាលហ្នឹង?

សុខុម ៖ មីនច្រើន!បើនិយាយពីមីនវិញមីនលែងនិយាយហើយ ដើរប្រហែសដាច់ជើងបាត់លូវហើយ ចុះបើមីនវាប្របូកប្របល់គ្នា ខាងនេះក៏ដាក់ខាងនោះក៏ដាក់ ប្រលូកប្រលំគ្នា ហើយតែយើងអត់ប្រយ័ត្នសាប់ខ្លួនឯងហើយ ។

ដានី ៖ ដូចផ្ទះនៅអី យើងត្រូវតែភាវចេញហើយបានធ្វើ?

សុខុម ៖ បាទ!ភាវចេញហើយបានធ្វើ ។

ដានី ៖ ភាវអញ្ចឹងវាមានគ្រោះថ្នាក់ច្រើនទេ?

សុខុម ៖ វាអាចគ្រោះថ្នាក់ដែរដោយចៃដន្យ ប៉ុនភាគច្រើនវាអត់បញ្ហាអ្នកភាវ បើថាអត់ភាវវារឹតតែគ្រោះថ្នាក់ហើយ បើថាយើងភាវទៅវាមួយៗទេ ដូចថាបច្ចេកទេសយើងអត់ទៅយើងអត់ដឹងរឿងវាអាចគ្រោះថ្នាក់ដែរ ។

ដានី ៖ បាទ!អញ្ចឹងពី៨៩ម៉ោវិញ យើងភាវមីន យើងធ្វើផ្ទះនៅជាគ្រួសារ យើងរកស៊ីខ្លួនឯងឬក៏យ៉ាងម៉េច?

សុខុម ៖ យើងធ្វើនៅតែប្រពន្ធកូនទេ ខ្លួនយើងគេប្រើ ។

ដានី ៖ តែរបបអីគេចែក?

សុខុម ៖ បាទ!គេចែកឲ្យតែប្រពន្ធកូនយើងទេ យើអទាល់តែម៉ោសមរមុខវិញបានគេឲ្យស៊ី ។

ដានី ៖ កាលហ្នឹងយើងអត់មានធ្វើចំការអី?

សុខុម ៖ កាលហ្នឹងមានពេលណាធ្វើ ពេលតែគេឲ្យរត់បាញ់គ្នាហ្នឹង ។

ដានី ៖ កាលហ្នឹងពេលដែលយើងម៉ោវិញហ្នឹងគេនៅតែបាញ់គ្នាអញ្ចឹង?

សុខុម ៖ ហ្នឹងហើយ ម៉ោនៅតែបាញ់គ្នាហ្នឹង បាញ់គ្នាទាល់តែដាច់ខ្លួនហ្នឹង ។

ដានី ៖ បាទ!អញ្ចឹងសមរភូមិទៅខាងណាវិញទៅអញ្ចឹង?

សុខុម ៖ សមរភូមិទៅមុខថ្នល់ជាតិលេខ៥ហ្នឹង ទៅបវេល ។

ដានី ៖ តែកាលហ្នឹងផ្ទះយើងមិនទាន់បានធ្វើធំៗអញ្ចឹងទេ?

សុខុម ៖ នៅ អាខ្លះធ្វើធំៗហើយ ផ្ទះខ្ញុំនេះធ្វើតាំងពី៩២ដែរហ្នឹង ក្រោយម៉ោទៅ កាលហ្នឹងខ្មែរក្រហម៩១គេឲ្យរំសាយ កាលសម័យអ៊ុន តាក់ ខ្ញុំសុំគេឈប់ក្លាម គេក៏ឲ្យឈប់ឲ្យអង្ករ១បាវ ។

ដានី ៖ អ៊ូ! ពេលសម័យអ៊ុន គាត់គេឲ្យឈប់?

សុខុម ៖ ហ្នឹងហើយខាងក៏គេឲ្យឈប់ដែរ គេថាកាត់បន្ថយកងទ័ពមួយចំនួន ខ្ញុំក៏ដាក់ឈ្មោះសុំគេ ភ្លាម ខ្ញុំថាសុំគេឈប់ហើយ ។

ដានី ៖ ម៉េចអញ្ចឹង?

សុខុម ៖ អ្នកដឹកនាំគេមិនដឹងយ៉ាងម៉េចព្រោះតែអ្នកដឹកនាំគេឲ្យឈប់ សុំឈប់តែម្តង ។

ដានី ៖ អត់ចង់ធ្វើតទៀត?

សុខុម ៖ អត់ចង់ធ្វើទេ ចង់រកស៊ីអីអញ្ចឹងទៅ ខ្ញុំអារឈើខ្វះទៅ ហើយក្រោយមកទៀតគេរៃទៀតៗ គេហៅយើងចូលម្តងទៀត ចូលទៅម្តងទៀតទល់តែផ្តាច់ខ្លួនបានខ្ញុំសុំគេឈប់ទៀតចប់រហូត ។

ដានី ៖ អញ្ចឹងផ្តាច់ខ្លួនឆ្នាំ៩៦?

សុខុម ៖ បាទ!

ដានី ៖ អញ្ចឹងពេលផ្តាច់ហ្នឹងពូសុំគេដាច់ម៉ង?

សុខុម ៖ សុំគេឈប់ទៅ ។

ដានី ៖ អត់មាននៅក្នុងក្របខ័ណ្ឌអី?

សុខុម ៖ អត់ៗមានចង់ធ្វើអីទៀតទេ ព្រោះវារៀងហើយ គិតៗទៅវាអត់បានប្រយោជន៍អី ។

ដានី ៖ អញ្ចឹងផ្តាច់តាំងពីឆ្នាំ៩៦ហ្នឹងម៉ោឈប់រហូត?

សុខុម ៖ ឈប់ធ្វើរហូ ៗត

ដានី ៖ ចុះដូចកាលហ្នឹងដាច់ឆ្នាំ៩៦ម៉ោ ដូចដីធ្លី ផ្ទះសម្បែងអីយើងចាប់ខ្លួនឯងឬគេចែករបបឲ្យយើង?

សុខុម ៖ យើងចាប់ទេ ដូចថាមុនយើងនៅតាមកងគេ គេកាប់ៗចែកឲ្យគ្នានៅទៅ អ្នកណាកាប់បានច្រើន បាននៅទៅ ។

ដានី ៖ ចុះដីស្រែដីចំការ?

សុខុម ៖ អាហ្នឹងក៏យើងចែកគ្នាកាប់ៗ អ្នកណាកាប់ទៅក៏បានអ្នកណាខ្ជិលក៏អត់ទៅ ដូចរកស៊ីសព្វថ្ងៃអញ្ចឹង ។

ដានី ៖ ចុះពូចាប់បានប៉ុន្មានដែរ ដីស្រែដីចំការ?

សុខុម ៖ ហ៊ឺ! បានបន្តិចដែរដីចំការ ។

ដានី ៖ បានប៉ុន្មានហិចតា?

សុខុម ៖ បាន១០ហិចតាដាង ហើយអាជិត១នេះ ព្រោះខ្ញុំយល់ថាវាធ្វើទៅវាលំបាក ព្រោះខ្ញុំរៀនអត់បានជ្រៅជ្រះទេ តែរាល់ថ្ងៃខ្ញុំចេះតែសិក្សា១ទៅយើងកំព្រា យើងសិក្សាទៅអត់ប្រយោជន៍ទេ ព្រោះវាសង្គ្រាម បើយើងធ្វើត្រូវទៅវាសសើរយើង បើយើងធ្វើខុសទៅវាស្តីឲ្យយើងដូចឆ្កែអញ្ចឹង អញ្ចឹងបានខ្ញុំអត់ចង់ធ្វើ ។

ដានី ៖ ចុះពូកាលហ្នឹងយើងអត់មានចង់នៅធ្វើកងទ័ពទៀតទេ ព្រោះយើងនៅមានប្រាក់ខែ?

សុខុម ៖ ហ៊ឺ!អត់ចង់បានទេ ចាញ់រកស៊ីទេ ធ្វើទ័ពវាហេងសយ១គ្រាប់ជួនវាប់១គ្រាប់ជួនរស់អានេះប៉ះគេអត់វ៉ៃគ្នា បើគេវ៉ៃគ្នា យើងស៊ីប្រាក់ខែគេយូរគេអាចយកទៅដល់គ្នាទៀតម៉េចយើងស៊ីប្រាក់ខែគេយូរហើយ បើយើងមិនទៅម៉េចយើងស៊ីប្រាក់ខែគេយូរហើយខ្ញុំមិនចង់បានទេ ចង់បានកម្លាំងខ្ញុំរកស៊ីវិញ អត់បានជំនួយអីទេ ដូចច្នេះយើងដឹងប្រវត្តិយើងវាលំបាកខ្លាំងណាស់ ។

ដានី ៖ ចុះពូដូចថាយើងបែកពីផ្ទះ តាំងពីឆ្នាំ៧០ដាង តើឆ្នាំណាបានយើងបានទៅលេងផ្ទះ វិញ?

សុខុម ៖ កាលផ្តាច់ខ្លួនហើយខ្ញុំទៅលេងភ្លាម ។

ដានី ៖ ផ្តាច់ខ្លួនហើយភ្លាមទៅរកផ្ទះឃើញដែរ?

សុខុម ៖ ឃើញ ទៅដល់ម៉ែស្លាប់បាន១ឆ្នាំ នៅសល់តែបង១ ។

ដានី ៖ បងប្អូននៅទាំងអស់?

សុខុម ៖ នៅទាំងអស់បែកតែមួយទេ ។

ដានី ៖ ចុះមានអារម្មណ៍យ៉ាងម៉េចដែរ ពេលដែលយើងទៅលេងផ្ទះដំបូង?

សុខុម ៖ វារន្ធត់ដែរហ្នឹងបាត់ម្តាយទៅ យើងម៉ោថាឲ្យទាន់ដង្ហើមគាត់ខ្ញុំចង់ឃើញគាត់ តែមិនដឹងខ្ញុំចង់ទៅយូរយារណាស់ហើយ តែយើងមិនដឹងធ្វើម៉េចទៅជួបម្តាយយើងរួច បើយើងទៅតែមិនស្រួលគេដាក់យើងចោលខាងនេះ បើយើងទៅខាងនោះក៏គេថាយើងដាក់ចោលនៅខាងនោះ ចេះតែទ្រាំ១នៅឲ្យតែរស់១សិនទៅ ទំរាំដល់ថ្ងៃណាគេត្រូវគ្នា តែខ្ញុំគិតឃើញថាវាជៀសត្រូវគ្នាអត់រួច ខ្ញុំគិតតាំងពីខ្ញុំចូលពីដីថៃឆ្នាំ៩១ តាំងពីបោះឆ្នោតអ៊ុន តាក់ នោះវាចៀសត្រូវគ្នាអត់រួចទេ ព្រោះខ្ញុំធ្លាប់នៅជាមួយអ្នកដឹកនាំច្រើនទៅខ្ញុំដឹងតែខ្ញុំអត់មាត់ ពុសុខភាពក៏និយាយ ឈៀង វុធ ក៏និយាយ ខ្ញុំមិនមែនជាដឹកនាំអីទេ តែខ្ញុំធ្លាប់នៅជាមួយគេ ប៉ុនជិហរល្អ ជិហររបស់សុខភាពល្អ ។

ដានី ៖ និយាយពីការយើងរួបរួមគ្នាហ្នឹង?

សុខុម ៖ ហ្នឹងហើយ ឥឡូវយើងនិយាយបានហើយ តែពីមុនយើងនិយាយមិនបានទេ សុខភាព គាត់ចេះតែនិយាយប្រាប់ទៅ គាត់ថាក្មេងខ្ញុំមួយជាក្មេងមិននិយាយមិនទៅណា ហើយក៏មិនចេះអួតអាងឮហើយក៏មិនចេះ អ្នកណាសួរខ្ញុំក៏ខ្ញុំមិនចេះ តែស្តាប់ឮៗតែខ្ញុំហ្នឹងឯង តែសួរខ្ញុំអត់ដឹងរឿងដែរ ព្រោះថារឿងរបស់គេយើងទៅដោះស្រាយក៏អត់កើតដែរ យើងទៅនិយាយក៏អត់កើតដែរ អញ្ចឹងយើងដើម្បីការពារជីវិតយើងដ៏តែយើងធ្វើ អញ្ចឹងតែខ្ញុំអត់ចេះអាអញ្ចឹងទេ តែខ្ញុំដឹងរឿងគេច្រើនគឺផាប់ខ្ញុំហើយ ។

ដានី ៖ ចុះពេលដែលយើងទៅផ្ទះដំបូង ដូចថាយើងបែកគ្នាយូរអញ្ចឹងបងប្អូនមើលគ្នាស្គាល់គ្នាដែរ?

សុខុម ៖ ស្គាល់គ្នាបងប្អូនខ្ញុំ ។

ដានី ៖ ស្គាល់គ្នាមើលទៅចំណាំគ្នា?

សុខុម ៖ បាទ!ចំណាំគ្នា ។

ដានី ៖ បែកគ្នាប៉ុន្មានឆ្នាំ?

សុខុម ៖ យូរដែរ តាំងពី៧៣ម៉ោ ទល់ផ្តាច់ខ្លួនថ្ងៃមុននេះទៅ ទៅដើរហួសផ្ទះ ដល់ទៅជួប មីងខ្ញុំ ។

ដានី ៖ ទៅដំបូងមីងអត់ស្គាល់ដែរ?

សុខុម ៖ អត់ស្គាល់ បងៗខ្ញុំក៏អត់ស្គាល់ដែរដ៏មួយសន្ទុះទើបគាត់ដឹងថាប្អូន ។

ដានី ៖ យើងដើរទៅដំបូងអត់ទាន់ប្រាប់អីគាត់អត់ទាន់ស្គាល់ពូទេ?

សុខុម ៖ អត់ៗទាន់ស្គាល់ទេ ។

ដានី ៖ វារំភើបទេកាលហ្នឹង?

សុខុម ៖ វាស្តុតចិត្តទៅម៉ែបាត់ឈឹង ខ្ញុំរន្ធត់ចិត្តណាស់បាត់ម្តាយទទេអត់ប្រយោជន៍ ជាប់គុក ហើយសួរប្រវត្តិ បងខ្ញុំនិយាយប្រាប់ថា គេយកអញដាក់គុកព្រៃស ម្តាយហែងបងប្អូនទាំងអស់ហ្នឹង អញទីមរួច៧៩ហ្នឹង ម្តាយឯងគាត់គាំគ្រារអញ្ចឹងបានគាត់ស្លាប់ហ្នឹង ខ្ញុំស្រក់ទឹកភ្នែកម៉ង ធ្វើអីមិនចេញទេ អញ្ចឹងបានខ្ញុំឡើងឆ្អែត តស៊ូឆ្អែតវាអត់បានប្រយោជន៍អីបើគិតទៅ មានប្រយោជន៍មិនមានប្រយោជន៍ខ្ញុំចាញ់បោកគេ ព្រោះខ្ញុំនៅតូច ខ្ញុំយល់តែខ្លួនខ្ញុំអញ្ចឹង អ្នកណាថាអីថាទៅ ប៉ុនខ្ញុំថាខ្លួនខ្ញុំតូចខ្ញុំគំនិតអត់ឈ្លាស វើបើខ្ញុំចាញ់គេខ្ញុំគ្មានគំនិតនៅខាងនេះទេខ្ញុំមិននៅជាមួយទេ ខ្ញុំទៅហើយ ខ្ញុំទៅជាមួយឪខ្ញុំហើយខ្ញុំរកក្រឡាឃើញហើយ ប៉ុន្តែយើងតូចយើងមិនដឹងទៅរកណា ហើយពីនេះទៅតាកែវមិនជិតណា មិនដឹងទៅប្រឡោះណាឥឡូវ ហើយគេឃោសនាយកទៅ នោះ

ហើយឲ្យយើងធ្វើម៉េចបើយើងចាញ់ឃោសនាគេហើយ មូលហេតុអី? មូលហេតុយើងរៀនអត់បានជ្រៅជ្រះ ខ្ញុំយល់ថាខ្ញុំអញ្ចឹង ឥឡូវខ្ញុំចេះដឹងខ្លះៗហើយ ខ្ញុំកាន់តែយល់ៗមែនទែនហើយ មិនថាមិនចេះដឹងទេ ចេះដឹងយូរហើយតែយើងរកផ្លូវទៅអត់ឃើញទេ ចាញ់ឧបាយរបស់គេផង ។

ដានី : ផ្ទះទៅលេងបានប៉ុន្មានថ្ងៃដែរ?

សុខុម : ទៅលេងយូរហើយ កន្លះខែហើយ ក្រោយម៉ោ២-៣ឆ្នាំទៅ ២-៣ឆ្នាំទៅ ។

ដានី : ទៅផ្ទះនឹកនេះវិញដែរឬអត់?

សុខុម : នឹក!

ដានី : ដូចថាអារម្មណ៍យ៉ាំងម៉េចដែរដូចថាពូធ្លាប់នៅនេះយូរហើយ ដូចស្រុកកំណើតយើងនៅពីក្មេង ដល់ពេលធំឡើងយើងនៅនេះ?

សុខុម : ប៉ុនអត់ទេអារម្មណ៍ខ្ញុំវាមយ៉ាំងដែរ ចង់ទៅនៅនោះក៏បាននៅនេះក៏បាន ព្រោះទឹកដីនោះក៏យើងធ្លាប់នៅ ទឹកដីនេះក៏យើងធ្លាប់នៅ ប៉ុនថាគំនិតមួយខ្ញុំគិតថាទៅនៅនោះដីវាចង្អៀតវាពិបាករកស៊ីគ្មានអីចិញ្ចឹមជីវិតបងប្អូនវាច្រើន ក្មួយក៏ច្រើនអញ្ចឹង វាអត់មានដីបង្កបង្កើនផល នៅនេះយើងមានដីស្រាប់ទូលាយយើងនៅនេះទៅអញ្ចឹង បើយើងចង់ទៅលេងជិះឡានទៅលេងទៅ ។

ដានី : ចុះមិត្តភក្រ័ពីតូចៗដូចគ្នាធ្លាប់ស្គាល់គ្នាពេលទៅនៅរាប់អានគ្នាទេ?

សុខុម : នៅរាប់អានគ្នាដូចមុនអញ្ចឹង ។

ដានី : ជិតស្និតដូចពីមុនទេ?

សុខុម : បាទ!ដូចតែគ្នាហ្នឹង ពីមុនម៉េចឥឡូវអញ្ចឹង ។

ដានី : ប៉ុន្តែដូចថាអ្នកនៅនេះ អ្នកដែលម៉ោនៅជាមួយគ្នាយូរ ស្រឡាញ់គ្នាដូចបងប្អូនដូចថាស្និតស្នាល២០-៣០ឆ្នាំមកដល់ឥឡូវ វានៅមានភាពស្និតស្នាលនឹងគ្នាដដែល ឬយ៉ាំងម៉េច?

សុខុម : ដូចតែគ្នា អត់កែប្រែ ព្រោះគំនិតខ្ញុំអត់ដូចថាមនុស្សខុសប្លែកពីគេខ្ញុំ ខ្ញុំមានឬអត់ អត់ដូចមាន អ្នកស្គាល់នៅតែស្គាល់ អ្នកស្រឡាញ់គ្នានៅតែស្រឡាញ់គ្នារាប់អានគ្នារហូតមកដល់ឥឡូវនេះ បងៗដែលធ្លាប់ជួយខ្ញុំហ្នឹង គាត់ហៅខ្ញុំទៅធ្វើអីទៅគាត់ដេក៏ដេទៅ ខ្ញុំរាប់អានគាត់ដូចបងខ្ញុំបង្កើតអញ្ចឹង ព្រោះខ្ញុំមនុស្សវាកំព្រា ខ្ញុំទៅណាគេរាប់អានខ្ញុំ

ស្រឡាញ់ខ្ញុំ ដូចមីងអញ្ចឹងគាត់ដេរអីក៏ដេរទៅ ថាអីក៏ថាទៅបើវាកំព្រាអញ្ចឹង អារម្មណ៍ខ្ញុំនៅតែអញ្ចឹងនៅតែស្រឡាញ់គ្នាអញ្ចឹង ។

ដានី ៖ ចុះមួយទៀត ឥឡូវហ្នឹងនៅភ្នំពេញគេបង្កើតតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ក្នុងនោះដូចថាមាន អៀង សារី អញ្ចឹងដែរ តើពូគិតថាគេបង្កើតតុលាការហ្នឹងត្រឹមត្រូវដែរឬមិនត្រឹមត្រូវទេ?

សុខុម ៖ វាត្រឹមត្រូវហើយ រឿងជាអ្នកដឹកនាំ ដូចឪពុកអញ្ចឹងតែកូនខូចមានតែឪពុកហ្នឹងហើយ ប៉ុនមែនទែនមានកូនខូចណា ឪពុកខូច ខ្ញុំយល់ជាការត្រឹមត្រូវធ្វើហ្នឹងមិនខូចទេ បើតាមខ្ញុំយល់អត់ខុសទេ បុគ្គលគេគ្រប់គ្នាខ្ញុំមិនដឹងទេ តែបុគ្គលខ្ញុំនៅក្នុងគេប្រើខ្ញុំដែលខ្ញុំអត់ដឹងអីផង ពួកហ្នឹងដែលប្រើខ្ញុំពួកហ្នឹងដែលចង់សម្លាប់ខ្ញុំ ហៅខ្ញុំទៅសាប់ហៅខ្ញុំឲ្យចូលព្រៃ ពួកហ្នឹងហើយដែលធ្វើនយោបាយឲ្យខ្ញុំឆប់ឆល់មិនអាចទៅដុះវិញរួច ខ្ញុំថាជាការត្រឹមត្រូវ ព្រោះអ្នកដឹកនាំប៉ុន្មាននាក់ហ្នឹងហើយដែលធ្វើឲ្យប្រទេសជាតិអញ្ចឹង បើកុំអញ្ចឹងខ្ញុំទៅជួបម៉ែឪខ្ញុំនោះ ខ្ញុំមិនបានម៉ោដល់នៅនេះទេ ខ្ញុំទៅជួបបងប្អូនខ្ញុំនៅស្រុកនោះមិនល្អជាង អត់មានដីធំមែនក៏ជួបមូលមីបងប្អូនក៏ដឹងថាម៉ែខ្ញុំស្លាប់ថ្ងៃនេះ ម៉ែខ្ញុំគាត់ឈឺរោគចេះស្លាប់ ខ្ញុំថាជារឿងត្រឹមត្រូវ ហើយម៉ែខ្ញុំចាស់ហើយគាត់អត់មានដឹងរឿងអីសោះ ហេតុអីខុសអ្នកដទៃហៅតែមាំក្រុមគ្រួសារខ្ញុំយកទៅដាក់គុកដែរ សួរគាត់ក្បត់អីគេ អត់មានក្បត់អីផងហ្នឹង គ្រាន់តែថាដូចបងឯងហើយនឹងខ្ញុំធ្លាប់នៅជាមួយគ្នា ៗដូចបងឯងខូចអញ្ចឹងគេចោទថាបងក្បត់អញ្ចឹង គេយកបងឯងទៅហើយគេចាប់ទាំងគ្រួសារបងឯងទៅទៀត សួរថាអាហ្នឹងវាត្រឹមត្រូវទេ បើយើងអត់ដឹងផងហ្នឹង គ្រាន់តែនៅអន្តភាពជាមួយគ្នា យកមាំអន្តភាពជាមួយគ្នាយកមាំអន្តភាពទៅទាំងអស់ ជាប់គុក៧៩ចេញដែរ ខ្ញុំមិនទេ ខ្ញុំអន់ចិត្តត្រង់ហ្នឹងដែរ ព្រោះថាសម័យហ្នឹងវាធ្វើអីវាធ្វើអត់យុត្តិធម៌ គ្នាមិនខុសក៏ថាគ្នាខុសដែរ ប៉ុនការកាត់ទោសនេះវាល្អហើយ គាត់អ្នកធ្វើទើបគាត់អ្នកទទួល គាត់អ្នកចងគាត់ស្រាយ មិនមែនពួកខ្ញុំនេះអ្នកស្រាយអ្នកអីគេទេ ខ្ញុំនេះជាខ្ញុំបំរើគេទេ ជាស្តែមួយគុម្ពទេ គេដាំហើយសម្រាប់កេដកស៊ីទេ និយាយមួយមាត់ទៅស្តែមួយគុម្ពគេដាំហើយគេដកស៊ី គេចង់ទុកវាឲ្យដុះហ្នឹងហើយគេក្តិចផ្កាវាហើយយកគ្រាប់របស់វាទៅរោយផ្សាំសាថ្មីទៀតជារឿងរបស់គេទេ យើងគ្រាន់តែដើមឈើមួយដើមសម្រាប់គេកាប់ហើយដុះបំពង់ៗទេ ខ្ញុំយល់អញ្ចឹង អ្នកខ្លះគេថាចេះថាចុះខ្ញុំថាខ្ញុំអារម្មណ៍មិនដូចគេទេ ខ្ញុំមិនគិតដូចគេទេអ្នកឯងថាម៉េចថាចុះ តែខ្ញុំអារម្មណ៍ខ្ញុំគិតតែ

វាអញ្ចឹង បើយើងយល់ឲ្យដល់មានខ្ញុំជាអ្នកដឹកនាំទេ គាត់ខាងលើនោះជាអ្នកដឹកនាំ ខ្ញុំដូចខ្ញុំថាអញ្ចឹង ខ្ញុំគ្រាន់តែជាស្តែសម្រាប់គាត់ដាំ ចង់គាត់កាប់ៗចង់គាត់ដកៗ អញ្ចឹងបានថារឿងខុសត្រូវលើគាត់នៅលើ ខ្ញុំមានដឹងណា អញ្ចឹងបានថាខ្ញុំបានរស់នៅតំបន់នេះតាំងពីឆ្នាំ៧៩ម៉ោក៏ដោយសារចាញ់បោកពួកគាត់ដែរ បើមិនចាញ់បោកពួកគាត់ខ្ញុំមិនបែកពីម៉ែពីឪតាំងពីនៅតូចៗទេ ខ្ញុំយល់អញ្ចឹង តែអ្នកណាគេថាអីថាគេយល់ម៉េចខ្ញុំអត់ទាក់ទងជាមួយគេ ខ្ញុំយល់អារម្មណ៍របស់ខ្ញុំ បើកុំតែគាត់ស្មានតែខ្ញុំបែកពីម៉ែឪខ្ញុំខ្ញុំសួរមើល៎ ម៉ែឪខ្ញុំគាត់រកប្រពន្ធឲ្យនៅជិតៗគាត់នោះមិនស្រួល មិនបានបែកនៅឆ្ងាយបែកយ៉ាំងច្រើនម៉ាស្រុកពីរស្រុកជិតៗគ្នានោះ អាហ្នឹងវាអញ្ចឹង ដូច្នេះបងឯងសួរថាការកាត់ទោសវាត្រឹមត្រូវទេ? ការកាត់ទោសវាត្រឹមត្រូវហើយវាអត់ខុសទេ បើអ្នកណាថាខុសខ្ញុំអត់យល់ស្របទេ វាជាការត្រឹមត្រូវ ។

ដានី ៖ អញ្ចឹងខ្ញុំដូចជាអស់សំនួរអីសួរពូទៀតហើយ ពូមានអីចង់បន្ថែមទេ?

សុខុម ៖ អត់ៗទេ!

ដានី ៖ បាទ!អញ្ចឹងខ្ញុំអរគុណច្រើន!

សុខុម ៖ បាទ!

«ចប់»